សុន្ទរកថាគន្លឹះ
របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
ថ្លែងនៅក្នុង «វេទិកានៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី ២»
រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០០៨

****+****

- ឯកឧត្តមប្រធានវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា

- ឯកឧត្តម លោកជំទាវតំណាងដ៏ខ្ពង់ខ្ពស់របស់ប្រទេស និង ភ្នាក់ងារជាដៃគូ

- ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃរាជរដ្ឋាភិបាល កម្ពុជា

- ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និង អន្តរជាតិ

1. ថ្ងៃនេះ ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់និងសេចក្តីសោមនស្សជាអនេក ដោយបានមកជួបប្រជុំជាថ្មីម្តងទៀត ជាមួយតំណាងរបស់សហគមន៍អន្តរជាតិ និងដៃគូអភិវឌ្ឍន៍ ។ ខ្ញុំសូមសម្តែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ ជូនចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការចូលរួមក្នុង ***«វេទិកានៃកិច្ចសហប្រតិបត្តិការ អភិវឌ្ឍន៍កម្ពុជា»*** *(Cambodia Development Coopera-tion Forum-CDCF)* លើកទី ២ នាពេលនេះ ។ នេះគឺជាកិច្ចប្រជុំលើកដំបូងនៃវេទិកា នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាសម្រាប់រាជរដ្ឋាភិបាលថ្មីក្នុងនីតិកាលទី ៤ នៃរដ្ឋសភា នេះ ។

2. ជាកិច្ចចាប់ផ្តើម ខ្ញុំសូមសម្តែងនូវការដឹងគុណដ៏ជ្រាលជ្រៅសារជាថ្មីម្តងទៀត ជូនចំពោះជនរួមជាតិទាំងអស់ដែលបានផ្តល់សេចក្តីជឿទុកចិត្តជាលើកទី ៤ មកលើរូបខ្ញុំ ក្នុងការបន្តដឹកនាំប្រទេសតាមរយៈការបោះឆ្នោតជាសកលនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៨ កន្លងទៅថ្មីៗនេះ ។ សេចក្តីជឿទុកចិត្តទាំងស្រុងនេះបានផ្តល់ទាំងកិត្តិយស និងស្មារតីភក្តីដ៏ជ្រាលជ្រៅចំពោះរូបខ្ញុំ ក្នុងការបន្តបម្រើជាតិ និងប្រជាជនជាទីស្រឡាញ់ ក្នុងឋានៈជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។ ជាការពិតលទ្ធផលនៃការបោះឆ្នោតនេះ ក៏គឺជាការឆ្លុះបញ្ចាំងឱ្យឃើញផងដែរ នូវឆន្ទៈគាំទ្រយ៉ាងពេញលេញ និងមោះមុតពីសំណាក់ប្រជាពលរដ្ឋដ៏ច្រើនលើសលប់ និងពីគ្រប់មជ្ឈដ្ឋានទៅលើភាពចាំបាច់ក្នុងការបន្តកិច្ចដឹកនាំកសាងប្រទេស នៅលើមាគ៌ានៃការអភិវឌ្ឍន៍ និងកំណែទម្រង់រដ្ឋក្នុងគ្របវិស័យឆ្ពោះទៅរកវឌ្ឍនភាព និងវិបុលភាពដ៏រុងរឿងស្របតាមកម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជា

ដែលយើងខ្ញុំបានដាក់ជូនប្រជាជនកម្ពុជាទាំងមូលធ្វើការវិនិច្ឆ័យ នៅមុនការបោះឆ្នោតហើយដែលបច្ចុប្បន្នបានក្លាយទៅជា «**កម្មវិធីនយោបាយ**» របស់រាជរដ្ឋាភិបាលនីតិកាលទី ៤ នេះ ។

3. លើមូលដ្ឋាននេះរាជរដ្ឋាភិបាលកម្ពុជាដែលបង្កើតឡើងដោយឆន្ទៈពិតប្រាកដរបស់ប្រជាពលរដ្ឋនេះ ពិតជាមានការប្តេជ្ញាចិត្តឥតរាថយ ក្នុងការបន្តអនុវត្តអាណត្តិកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវខ្ពស់បំផុត ដោយតម្កល់ផលប្រយោជន៍ជាតិ និងបំណងប្រាថ្នារបស់ប្រជាជនជាធំ ដើម្បីបុព្វហេតុនៃការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច ។ គឺនៅក្នុងស្មារតីនេះហើយ ដែលរូបខ្ញុំផ្ទាល់ក្នុងឋានៈជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាបានដាក់ចេញមក និងប្តេជ្ញាដឹកនាំជំរុញអនុវត្តឱ្យបានជោគជ័យនូវ«***យុទ្ធសាស្ត្រចតុកោណ***» ដើម្បី ***កំណើន ការងារ សមធម៌*** និង ***ប្រសិទ្ធភាព*** នៅកម្ពុជា ***ដំណាក់កាលទី ២*** ដែលជា ***«របៀបវារៈ គោលនយោបាយសង្គម - សេដ្ឋកិច្ច»*** *នៃ* ***«កម្មវិធីនយោបាយ»*** របស់រាជរដ្ឋាភិបាលនីតិកាល ទី ៤ នៃរដ្ឋសភានេះ ។

4. ក្នុងការអនុវត្តន៍***យុទ្ធសាស្ត្រចតុកោណ*** ក្នុងនីតិកាលទី ៣ កន្លងទៅនេះ យើងសម្រេចបានសមិទ្ធផលធំៗជាច្រើនដែលកំពុងមានឥទ្ធិពលជាវិជ្ជមានទៅលើការពង្រឹង កោសិកា និងវប្បធម៌សន្តិភាព សន្តិសុខ សុវត្ថិភាពសង្គម លទ្ធិប្រជាធិបតេយ្យ ហើយផ្តល់កាលានុវត្តភាពឱ្យរាជរដ្ឋាភិបាលអនុវត្តដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ និងបន្តអនុវត្តយ៉ាងហ្មឹងម៉ាត់នូវកម្មវិធីកំណែទម្រង់នានា ។ ទន្ទឹមនេះ សន្តិភាព ស្ថិរភាពនយោបាយ និងសេរីភាវូបនីយកម្មកំពុងចាក់គ្រឹះយ៉ាងរឹងមាំសម្រាប់ការពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងទាក់ទាញវិនិយោគទុន ដែលជាបុព្វលក្ខខណ្ឌមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងការកាត់បន្ថយភាពក្រីក្រ ។ ម៉្យាងវិញទៀត សមិទ្ធផលខាងផ្នែកសេដ្ឋកិច្ចនេះអាចសម្រេចបាន ក៏ដោយសារការខិតខំកសាងសមត្ថភាពស្ថាប័នរដ្ឋ និងការអនុវត្តនូវគោលនយោបាយអភិវឌ្ឍន៍សង្គម- សេដ្ឋកិច្ចប្រកបដោយភាពគត់មត់ ដោយមានការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់ប្រជាជនកម្ពុជា កិច្ចសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍នានានិង ការចូលរួមចំណែកយ៉ាងសកម្មពីវិស័យឯកជន ។ ឆ្លៀតក្នុងឱកាសនេះក្នុងនាមរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាទាំងមូល ខ្ញុំសូមថ្លែងនូវអំណរគុណដ៏ស្មោះអស់ពីដួងចិត្តជូនចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់ រួមទាំងវិស័យឯកជនដែលបានចូលរួមវិភាគទានដ៏ឧត្តុង្គឧត្តមមិនអាចកាត់ថ្លៃបាន ព្រមទាំងសង្ឃឹមយ៉ាងមុតមាំថា ដៃគូអភិវឌ្ឍន៍ទាំងអស់នឹងបន្តកិច្ចសហប្រតិបត្តិការបែបនេះជាដរាបតទៅ ។

5. ដូចពេលមុនៗដែរ យើងចូលរួមក្នុង«***វេទិកានៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា***» លើកនេះ គឺមិនមែនគ្រាន់តែដើម្បីធ្វើការបូកសរុបលទ្ធផលការងារវឌ្ឍនភាព និងពិនិត្យឡើងវិញនូវសកម្មភាពកំណែទម្រង់របស់យើង ក្នុងរយៈពេលកន្លងមកប៉ុណ្ណោះទេ ប៉ុន្តែយើងក៏នឹងធ្វើការពិគ្រោះយោបល់ផងដែរ លើទិដ្ឋភាពគន្លឹះផ្សេងៗនៃអភិក្រមជាយុទ្ធសាស្ត្រ ដើម្បីជំរុញកិច្ចដំណើរការអភិវឌ្ឍន៍កម្ពុជានាពេលខាងមុខ ។ ក្នុងន័យនេះ ខ្ញុំសូមអនុញ្ញាតគូសបញ្ជាក់ដោយសង្ខេបអំពីសមិទ្ធផលធំៗ ដែលយើងសម្រេចបានក្នុងរយៈពេលថ្មីៗកន្លងមក ហើយទន្ទឹមនឹងនេះដែរ ខ្ញុំនឹងលើកឡើងអំពីបញ្ហាប្រឈមសំខាន់ៗមួយចំនួន ដែលយើងបានជួបប្រទះ ព្រមទាំងដំណោះស្រាយជាវិធានការគោលនយោបាយ ដែលរាជរដ្ឋាភិបាលបានដាក់ចេញ ដើម្បីឆ្លើយតបទៅនឹងចំណាប់អារម្មណ៍របស់អស់លោកអ្នក ក៏ដូចជាដើម្បីទាក់ទាញការគាំទ្របន្ថែមទៀត ពីសំណាក់ដៃគូសហប្រតិបត្តិការទាំងអស់របស់យើង ។

- ឯកឧត្តម លោកជំទាវ លោក លោកស្រី !

6. រាជរដ្ឋាភិបាលនៅតែចាត់ទុកថា អភិបាលកិច្ចល្អ គឺជាបុរេលក្ខណៈវិនិច្ឆ័យសំខាន់បំផុតមួយដើម្បីធានាឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចិរភាព សមធម៌ និងយុត្តិធម៌ សង្គម ។ អភិបាលកិច្ចល្អតម្រូវឱ្យមានការចូលរួមយ៉ាងទូលំទូលាយ មានការលើកកម្ពស់ការចែករំលែកព័ត៌មានមានគណនេយ្យភាព និងតម្លាភាព មានភាពស្មើគ្នានៅចំពោះមុខច្បាប់ និងការប្រតិបត្តិតាមវិធាននៃច្បាប់ ។ ជារួមអភិបាលកិច្ចល្អ ជាសេចក្តីត្រូវការរបស់សង្គមកម្ពុជា ទាំងក្នុងពេលបច្ចុប្បន្ននិងក្នុងពេលអនាគត ។

7. រាជរដ្ឋាភិបាលបានពង្រឹងអភិបាលកិច្ចល្អ តាមរយៈកំណែទម្រង់រដ្ឋបាលសាធារណៈ ច្បាប់និងប្រព័ន្ធយុត្តិធម៌ ការលើកកម្ពស់សមត្ថភាព និងប្រសិទ្ធភាពនៃវិស័យសាធាណៈ ដោយរួមបញ្ចូលទាំងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនៅលើការដ្ឋានច្រើនផ្សេងៗគ្នា រួមមានការជំរុញអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់រដ្ឋបាលសាធារណៈ រួមទាំង ការងារវិមជ្ឈការនិងវិសហមជ្ឈការ ផងដែរ ។

8. រាជរដ្ឋាភិបាលនីតិកាលទី ៣ បានធ្វើសកម្មភាពជាក់ស្តែងជាច្រើនរួចមកហើយ ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ ក្នុងស្មារតីនេះ ទោះបីជាមិនទាន់មានច្បាប់ប្រឆាំងនឹងអំពើពុករលួយនៅឡើយក៏ដោយ ក៏រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ ជាពិសេស ទៅលើការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនេះ តាមរយៈការដាក់ចេញនូវផែនការសកម្មភាពអភិបាលកិច្ច

ការអនុម័ត និងការជំរុញអនុវត្តនូវវិធានការច្បាប់មុតស្រួចមួយចំនួន ដូចជាច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីគយ អនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈ បទបញ្ជារបស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងចំណូល មិនមែនសារពើពន្ធ ក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីរាជការ គយ និងរដ្ឋាករ ។ល។ ជាមួយគ្នានេះដែរ យន្តការត្រួតពិនិត្យនៃអាជ្ញាធរសវនកម្មជាតិ និង អធិការកិច្ចត្រូវបានពង្រឹង យន្តការសវនកម្មផ្ទៃក្នុងត្រូវបានបង្កើតឡើងនៅតាមគ្រប់ក្រសួង- ស្ថាប័នរដ្ឋ ជាពិសេសអង្គភាពប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយត្រូវបានពង្រឹង រួមជាមួយនឹងការដាក់ទណ្ឌកម្មខាងវិន័យ រដ្ឋបាល និងការបញ្ជូនទៅតុលាការនូវមន្ត្រីមួយចំនួនដែលបានប្រព្រឹត្តកំហុសពាក់ព័ន្ធនឹងអំពើពុករលួយ ។

9. រាជរដ្ឋាភិបាលយល់ច្បាស់ថា ច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ គឺជាមូលដ្ឋានគតិយុត្តិគន្លឹះមួយមិនអាចខ្វះបាន សម្រាប់ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយប្រកបដោយប្រសិទ្ធភាព ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលប្តេជ្ញាចិត្តមោះមុតឥតរាថយ ក្នុងការរៀបចំ និងជំរុញ អនុម័តច្បាប់នេះ ដោយបន្តកិច្ចសហការ ពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយ នឹងគ្រប់ភាគីពាក់ព័ន្ធ ដោយផ្អែកលើច្បាប់គោលដទៃទៀតដែលគប្បីត្រូវបានអនុម័តជាមុន សម្រាប់ជាមូលដ្ឋាននៃច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយនេះ ។ រាជរដ្ឋាភិបាលបានកែលម្អប្រព័ន្ធច្បាប់ និងប្រព័ន្ធយុត្តិធម៌ដោយ ផ្តោតជាសំខាន់ទៅលើការរៀបចំក្របខ័ណ្ឌច្បាប់ឱ្យបានរឹងមាំ ព្រមទាំងពង្រឹងសមត្ថភាព ឯករាជ្យ និងអព្យាក្រឹតភាពនៃស្ថាប័នតុលាការ ដែលជាកត្តាដ៏សំខាន់ក្នុងដំណើរការពង្រឹងនីតិរដ្ឋ ។ ក្នុងនីតិកាលទី ៣ កន្លងទៅនេះ ច្បាប់ចំនួន ១៤០ ត្រូវបានអនុម័ត ក្នុងនោះមានក្រមធំៗចំនួន ៣ គឺក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមរដ្ឋប្បវេណី ។ ទន្ទឹមនេះ វិធានការវិន័យត្រូវបានដាក់ចេញជាបន្តបន្ទាប់ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមព្រមជាមួយនឹងសមត្ថភាព និងការទទួលខុសត្រូវវិជ្ជាជីវៈចៅក្រម ក៏ត្រូវបានពង្រឹងតាមរយៈការបណ្តុះបណ្តាលដំបូងការបណ្តុះបណ្តាលបន្ត និងការអនុម័តក្រមសីលធម៌វិជ្ជាជីវៈចៅក្រម និងព្រះរាជអាជ្ញា ។ មជ្ឈមណ្ឌលសេវាយុត្តិធម៌ថ្នាក់ស្រុកមួយចំនួនត្រូវបានបង្កើតឡើងដើម្បីធ្វើស្ថាបនូបនីយកម្ម ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជាក្នុងទិសដៅកាត់បន្ថយការកកស្ទះសំណុំរឿង នៅតុលាការ ។

10. រាជរដ្ឋាភិបាលបានដាក់ឱ្យដំណើរការនូវកម្មវិធីអាទិភាពនៅតាមក្រសួង និងស្ថាប័នមួយចំនួន ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងរបស់ស្ថាប័ន បានរៀបចំលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើស និងរៀបចំឱ្យមានការប្រលងប្រជែងជ្រើសរើសមន្ត្រីរាជការបានតម្លើងប្រាក់ឧបត្ថម្ភគោលនយោបាយ ធានារ៉ាប់រងសង្គម ប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងបានអនុវត្តសាកល្បងនូវគំនិតផ្តួចផ្តើមផ្តល់ប្រាក់លាភការដោយផ្អែកលើលទ្ធផលការងារ ក្នុងគោលដៅពង្រឹង

សេវាសាធារណៈឱ្យមានប្រសិទ្ធភាព តម្លាភាព និងការទទួលខុសត្រូវខ្ពស់ និងបានដាក់ឱ្យដំណើរការសាកល្បងនូវយន្តការ ***«ច្រកចេញ-ចូលតែមួយ»*** ដើម្បីជួយសម្រួលដល់អ្នកប្រើប្រាស់សេវាសាធារណៈ និងបានដាក់ឱ្យដំណើរការវិមជ្ឈការថ្នាក់ ឃុំ-សង្កាត់ និងការផ្តល់សេវាតាម ប្រព័ន្ធព័ត៌មានវិទ្យា។ នៅក្នុងការដ្ឋានកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលសម្រេចបាននូវការធ្វើ ឱ្យមានភាពជឿទុកចិត្តបាន នៃថវិកាតាមរយៈការគ្រប់គ្រងចំណូលប្រកបដោយប្រសិទ្ធភាព និង ការធ្វើវិចារណកម្មចំណាយសាធារណៈ ។ ប្រាក់បៀវត្សមធ្យមប្រចាំខែបានកើនឡើងពី ៣០ ដុល្លារ ក្នុងឆ្នាំ ២០០៤ ដល់ ៦២,៤ ដុល្លារ ក្នុងឆ្នាំ ២០០៨ គឺកើនឡើងជាងទ្វេដង ។

11. ក្នុងនីតិកាលទី ៤ នេះ រាជរដ្ឋាភិបាលនឹងបន្តពង្រីកការអនុវត្តកន្សោមអាទិភាព និងការផ្តល់ប្រាក់លាភការដោយ ផ្អែកលើលទ្ធផលការងារនៅតាមក្រសួង និងស្ថាប័នតាមវិស័យអាទិភាពមួយចំនួនថែមទៀត ក្នុងគោលដៅអនុវត្តឱ្យស៊ីជម្រៅនូវកម្មវិធីកំណែទម្រង់តាមផ្នែករបស់រាជរដ្ឋាភិបាលនៅទូទាំងប្រទេស ។ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តគោលនយោបាយបង្កើន ប្រាក់បៀវត្សមូលដ្ឋានចំនួន ២០% ក្នុងមួយឆ្នាំ ធៀបទៅនឹងការបង្កើនពី ១០-១៥% ក្នុងនីតិកាល ទី៣ ។ រាជរដ្ឋាភិបាលនឹងបង្កើនការយកចិត្តទុកដាក់លើប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធ ព័ត៌មានវិទ្យា ការពង្រឹងការងារគ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ការពង្រីកតួនាទីស្ត្រីឱ្យចូលរួមកាន់តែសកម្មក្នុងរដ្ឋបាលសាធារណៈ ការពង្រឹងការផ្តល់សេវាសាធារណៈជាមូលដ្ឋាន សេវាអធិបតេយ្យរបស់រដ្ឋ សេវាពាក់ព័ន្ធទៅនឹងការវិនិយោគ និងពាណិជ្ជកម្មធុនតូច និង មធ្យម តាមរយៈការបន្តពង្រឹងសេវាសាធារណៈ ការអនុវត្តន៍យន្តការ ***«ច្រកចេញ-ចូលតែមួយ»*** និង ការបង្កើតការិយាល័យប្រជាពលរដ្ឋ ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងពង្រីកយន្តការថ្មីៗសម្រាប់ផ្តល់សេវាសាធារណៈ តាមរយៈការបង្កើត ***«ទីភ្នាក់ងារប្រតិបត្តិការពិសេស»*** នៅតាមបណ្តាក្រសួង-ស្ថាប័ន ព្រមទាំងជំរុញលើកទឹកចិត្តសង្គម ស៊ីវិល និងវិស័យឯកជនឱ្យចូលរួមចំណែកដោយផ្ទាល់ក្នុងការផ្តល់សេវាសាធារណៈ ។

12. រាជរដ្ឋាភិបាលនឹងបន្តជំរុញអនុវត្តគោលនយោបាយ វិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈការរៀបចំបទដ្ឋានគតិយុត្តិនិងការដាក់ចេញនូវវិធានការថ្មីថែមទៀត ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពនូវ ***« ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ»*** ជាពិសេស ការរៀបចំ និងអនុវត្តលិខិតបទដ្ឋាន ដែលពាក់ព័ន្ធនឹងការផ្ទេរអំណាចពីរដ្ឋបាលថ្នាក់ជាតិ មករដ្ឋបាលថ្នាក់ក្រោមជាតិ ដោយកំណត់ឱ្យបានច្បាស់លាស់នូវតួនាទី សិទ្ធិ អំណាច និងការធានាគណនេយ្យភាពក្នុងការបំពេញការងារ ។ ច្បាប់នេះនឹងត្រូវបានអនុវត្តជាជំហានៗដោយប្រុងប្រយ័ត្ន ដោយក្រសួងនិងស្ថាប័ននីមួយៗត្រូវរៀបចំផែនការជាក់ស្តែង ស្តីពីការធ្វើប្រតិភូកម្មអំណាច និងមុខងារដល់ថ្នាក់

ក្រោមជាតិ ។ ទន្ទឹមនេះដែរ ការគ្រប់គ្រងហិរញ្ញវត្ថុតាមបែបវិសហមជ្ឈការ នឹងត្រូវអនុវត្តដោយភាពទន់ភ្លន់ និងតាមដំណាក់ៗ ក្នុងរយៈពេលមធ្យម ដើម្បីមានពេលគ្រប់គ្រាន់ក្នុងការកសាងសមត្ថភាពថ្នាក់ក្រោមជាតិ សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ***គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ*** នឹងរៀបចំកម្មវិធីជាតិសម្រាប់ ការអនុវត្តន៍ក្នុងរយៈពេល ១០ ឆ្នាំ ។

13. ក្នុងនីតិកាលទី ៤ នេះ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តនូវកម្មវិធីកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ដើម្បីធានាបាននូវកិច្ចការពារប្រកបដោយប្រសិទ្ធភាពខ្ពស់ ដល់អធិបតេយ្យភាព និងបូរណភាពទឹកដី សន្តិសុខ និងសណ្តាប់ធ្នាប់សង្គមនៃព្រះរាជាណាចក្រកម្ពុជា ។

- ឯកឧត្តម លោកជំទាវ លោក លោកស្រី !

14. ក្នុងនីតិកាលទី ៣ កន្លងមក រាជរដ្ឋាភិបាលធានាបាននូវការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចប្រកបដោយស្ថិរភាព ដែលមានលក្ខណៈអនុគ្រោះសម្រាប់ការសម្រេចបាននូវវឌ្ឍនភាពសង្គមកិច្ច- សេដ្ឋកិច្ច ។

15. ក៏ប៉ុន្តែ វេទិកានៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី ២ នេះបានរៀបចំឡើងក្នុងបរិការណ៍នៃវិបត្តិកលិយុគហិរញ្ញវត្ថុដ៏ធ្ងន់ធ្ងរ ដែលកំពុងរីករាលដាលពេញពិភពលោក ។ វិបត្តិហិរញ្ញវត្ថុ ដែលបាននិងកំពុងកើតមាននៅសហរដ្ឋអាមេរិក និងបណ្តាប្រទេសអភិវឌ្ឍន៍ដទៃទៀតនាពេលបច្ចុប្បន្ននេះ គឺជាសក្ខីភាពមួយដែលឆ្លុះបញ្ចាំងពីការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោកដោយមិនអាចទស្សន៍ទាយបាន ដូចដែលពិភពលោកយើងធ្លាប់បានជួបប្រទះ ក្នុងមហាវិបត្តិសេដ្ឋកិច្ចពិភពលោកនាទសវត្សរ៍ ឆ្នាំ ១៩៣០ កន្លងទៅ ។

16. យ៉ាងណាក៏ដោយ ជារួមគិតចាប់ពីពេលពាក់កណ្តាលឆ្នាំនេះមក នៅពេលដែលពិភពលោកកំពុងមានវិបត្តិដោយសារការកើនឡើងថ្លៃប្រេង និងថ្លៃស្បៀងអាហារយ៉ាងគំហុកនោះ យើងពិនិត្យឃើញថា សេដ្ឋកិច្ចកម្ពុជានៅតែអាចរក្សាបាននូវកំណើនដដែល ប៉ុន្តែគ្រាន់តែកំណើននេះមានការថមថយចុះជាងមុន ។

17. ចំពោះវិស័យធនាគារ និងហិរញ្ញវត្ថុ ជាពិសេស ប្រតិបត្តិការរបស់ធនាគារនៅក្នុងប្រទេសបច្ចុប្បន្ន កំពុងមានសកម្មភាពដំណើការជាធម្មតា ដែលពុំមានអ្វីគួរឱ្យបារម្ភខ្លាំងនោះទេ ។ នេះដោយសាររាជរដ្ឋាភិបាលមានការគិតគូរទុកជាមុន តាមរយៈការដាក់ចេញនូវវិធានការជា កញ្ចប់ ដែលរួមមានគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយទ្រទ្រង់មួយចំនួនទៀត ដូចជាការតម្លើងអត្រាប្រាក់បម្រុងកាតព្វកិច្ច ការតម្លើងដើមទុនចុះបញ្ជីរបស់ធនាគារ និងការដាក់ពិដានឥណទាន

ចំពោះវិស័យអចលនទ្រព្យជាដើម ។ ម្យ៉ាងវិញទៀត វិស័យធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជាពុំទទួលរងផលប៉ះពាល់ធំដុំពីវិបត្តិ ដែលមានលក្ខណៈជាកលិយុគនៃហិរញ្ញវត្ថុអន្តរជាតិនោះទេ ដោយសារប្រតិបត្តិការរបស់ធនាគារកម្ពុជាបច្ចុប្បន្ន មិនទាន់មានទំនាក់ទំនងបើកចំហខ្លាំងទៅ នឹងប្រព័ន្ធហិរញ្ញវត្ថុខាងក្រៅ ជាពិសេសប្រតិបត្តិការធនាគារកម្ពុជាប្រើប្រាស់ប្រាក់បញ្ញើរបស់អតិថិជនក្នុងស្រុកធ្វើជាមូលដ្ឋាន។ ជាមួយគ្នានេះកម្ពុជាយើងក៏ពុំទាន់មានទីផ្សារទុនផងដែរ។

18. តាមការប៉ាន់ស្មានកំណើនសេដ្ឋកិច្ចតាមថ្លៃថេរនឹង សម្រេចបានក្នុងរង្វង់ ៧% នៅឆ្នាំ ២០០៨ នេះ ។ កំណើននេះមានកម្រិតទាបបន្តិចធៀបទៅឆ្នាំមុនៗ ដែលកំណើននេះបានកើនខ្ពស់បំផុតនៅឆ្នាំ ២០០៥ ដល់ទៅ ១៣,៣% ហើយបន្ថយល្បឿនមក ១០,៨% នៅឆ្នាំ ២០០៦ និង ១០,២% នៅ ឆ្នាំ ២០០៧ ។ ប្រការនេះបានធ្វើឱ្យភាពក្រីក្ររបស់ប្រជាជនថយចុះពីកម្រិត ៤៧% នៅឆ្នាំ ១៩៩៤ មក ៣៥%នៅឆ្នាំ ២០០៤ ហើយការប៉ាន់ស្មានក្នុងពេលថ្មីនេះបង្ហាញឱ្យឃើញថាអាត្រានៃភាពក្រីក្រនេះបានចុះមកនៅ ៣០% នៅឆ្នាំ ២០០៧ ។ ដូច្នេះក្នុងរយៈពេលនៃការពិនិត្យខាងលើនេះ ជាមធ្យមភាពក្រីក្របានថយចុះជាង ១% ក្នុងមួយឆ្នាំៗ ។

19. តាមថ្លៃថេរ វិស័យឧស្សាហកម្មអាចកើនឡើង ៥,៦% នៅឆ្នាំ ២០០៨ ។ ជារួមវិស័យឧស្សាហកម្មបានកើនឡើងយ៉ាងឆាប់រហ័សដែលសមាមាត្រនៃវិស័យនេះបានកើនដល់២៨,៩% នៅក្នុងឆ្នាំ ២០០៨ ឬកើនឡើងជាងទ្វេដងធៀបនឹងឆ្នាំ ១៩៩៣ ដែលមានចំនួន ១២,៧% ។ ប្រការនេះឆ្លុះបញ្ចាំងឱ្យឃើញនូវដំណើរការរីកចម្រើននៃឧស្សាកម្ម ជាពិសេសគឺការអភិវឌ្ឍន៍ឧស្សាហកម្មកាត់ដេរ ។ ទន្ទឹមនឹងនោះ វិស័យថាមពលដែលជាផ្នែកដ៏សំខាន់សម្រាប់ជាឧត្តមភាព នៃការប្រកួតប្រជែងរបស់សេដ្ឋកិច្ចផង និងជាគន្លឹះនៃការអភិវឌ្ឍន៍ជាតិផង កំពុងតែមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដែលអាចនឹងធានាឱ្យកម្ពុជាមានថាមពលអគ្គិសនីគ្រប់គ្រាន់ និងមានថ្លៃសមរម្យ ។ នៅឆ្នាំ ២០៣០ កម្ពុជារំពឹងថានឹងមានអគ្គិសនីប្រើប្រាស់ប្រមាណពី ៧០% ទៅ ១០០% តាមរយៈការបង្កើនសមត្ថភាពផលិតក្នុងប្រទេសផង និងការនាំចូលអគ្គិសនីពីប្រទេសជិតខាងផង រួមមានពីឡាវ ថៃ និងវៀតណាម ។ ប្រការនេះមានន័យថាប្រព័ន្ធអគ្គិសនីកម្ពុជានឹងធ្វើសមាហរណកម្មទៅក្នុងបណ្តាញប្រទេស ក្នុងមហាអនុតំបន់ទន្លេមេគង្គ និងអាស៊ាន ។

20. ដោយឡែក វិស័យកសិកម្មទោះបីសមាមាត្របានថយចុះក៏ពិតមែន ប៉ុន្តែការរីកចម្រើនមានសភាពខ្លាំងក្លា ។ នៅឆ្នាំ ២០០៨ កំណើនតាមថ្លៃថេរនៃវិស័យកសិកម្មអាចមានចំនួន ៣,៥% ដែលក្នុងនោះ ការផលិតស្រូវបានកើនឡើងលើសពីផែនការដែលបានគ្រោងទុក ។ វិស័យកសិកម្មមានការអភិវឌ្ឍន៍ប្រកបដោយស្ថិរភាពក្នុងកម្រិតខ្ពស់ ចាប់តាំងពីរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី ៣

នៃវដ្តសភាមក ដោយសារការរីកចម្រើនលើនយោបាយទឹក និងបច្ចេកទេសកសិកម្ម ដែលប្រការនេះកាន់តែដោះស្រាយបាននូវភាពរណបទៅនឹងការប្រែប្រួលកត្តាធម្មជាតិ ។ ការរីកចម្រើនវិស័យកសិកម្ម គឺជាកត្តាគន្លឹះសម្រាប់ការកាត់បន្ថយភាពក្រីក្រ ហើយក៏រួមចំណែកយ៉ាងច្រើនក្នុងកំណើនផលិតផលសរុបក្នុងស្រុក និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។

21. ជារួម ផ្ទៃដីកសិកម្មត្រូវបានស្តារលើសពីផ្ទៃដីកសិកម្មមុនសង្គ្រាម ហើយទិន្នផលស្រូវបានកើនឡើង ២,៥ ដង ធៀបនឹងពេលមុនសង្គ្រាម ។ វិស័យកសិកម្មនៅកម្ពុជាមានលក្ខណៈទំនើបជាបណ្តើរៗ តាមរយៈការកើនឡើងនៃការប្រើប្រាស់ជី និងការប្រើប្រាស់ពូជមានទិន្នផលខ្ពស់ ។ កំណើនតម្លៃបន្ថែមក្នុងវិស័យកសិកម្មបានកើនឡើងជាមធ្យម ៧,២% ក្នុងមួយឆ្នាំ រវាងឆ្នាំ ២០០៣-២០០៧ ធៀបទៅនឹង ១,៦% ក្នុងអំឡុងឆ្នាំ ១៩៩៨-២០០២ និង ៤,៩% ក្នុងអំឡុងឆ្នាំ ១៩៩៣-១៩៩៧ ។ ទិន្នផលស្រូវបានកើនឡើងជាលំដាប់ដល់ ២,៥ តោន ក្នុងមួយហិកតា នៅឆ្នាំ ២០០៧ ។

22. កំណែទម្រង់ដីធ្លី គឺជាផ្នែកមួយដែលមានវេទយិតភាពខ្ពស់ជាងគេ ដោយសារតែបញ្ហាដែលបន្សល់ទុកពីអតីតកាល។ ក្នុងការអនុវត្តច្បាប់ភូមិបាល និងគោលនយោបាយដីធ្លីរាជរដ្ឋាភិបាលផ្តោតជាសំខាន់លើវិធានការពង្រឹងប្រព័ន្ធគ្រប់គ្រង បែងចែក និងប្រើប្រាស់ដីធ្លី ការធានាសុវត្ថិភាពនៃកម្មសិទ្ធិដី ការលុបបំបាត់ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីដោយខុសច្បាប់ ការដាក់ចេញនូវវិធានការសមស្រប ដើម្បីទប់ស្កាត់ការប្រមូលដីទុកដោយមិនបានប្រើប្រាស់ និងមិនធ្វើផលិតកម្ម ។ ការចុះបញ្ជីដីជាប្រព័ន្ធបានទទួលការស្វាគមន៍ជាខ្លាំងពីប្រជាពលរដ្ឋនៅតាមតំបន់ជនបទ ។ ជាក់ស្តែងយើងបានផ្តល់កម្មសិទ្ធិដីជាង ១ លានក្បាលដី ។ គិតពី ឆ្នាំ ១៩៩២ មកដល់ ខែកុម្ភៈ ឆ្នាំ២០០៨ យើងបានបោសសម្អាតដីចម្ការមីនជាង ២០.០០០ ហិចតា ហើយគ្រោះថ្នាក់ដោយគ្រាប់មីនបានកាត់បន្ថយមួយដងកន្លះ ក្នុងរវាងពីឆ្នាំ ២០០៣ ដែលមាន ៨០០ ករណី មកត្រឹម ៣១៥ ករណី នៅឆ្នាំ ២០០៧ ។

23. កំណែទម្រង់ព្រៃឈើ និងកំណែទម្រង់ជលផលត្រូវបានអនុវត្តយ៉ាងសកម្មក្នុងគោលបំណងរក្សាប្រសិទ្ធភាព នៃការគ្រប់គ្រង និងការអភិវឌ្ឍធនធានធម្មជាតិប្រកបដោយចិរភាព ។ ក្នុងនោះរាជរដ្ឋាភិបាលបានទប់ស្កាត់ប្រកបដោយប្រសិទ្ធភាព នូវការធ្វើអាជីវកម្មឈើខុសច្បាប់ និងបានត្រួតពិនិត្យឡើងវិញនូវសម្បទានព្រៃឈើទាំងអស់ ។ សហគមន៍ព្រៃឈើចំនួន ២៦៤ ត្រូវបានបង្កើតដោយគ្របដណ្តប់ផ្ទៃដីជិត ១៨ ម៉ឺនហិកតា ដើម្បីចូលរួមការពារទ្រព្យសម្បត្តិដ៏មានតម្លៃនេះ ។ នៅក្នុងវិស័យជលផល សហគមន៍នេសាទប្រហែល ៤០០ ត្រូវបានបង្កើតឡើង។ គោលនយោបាយធនធានទឹកជាតិគឺជាផ្នែកមួយនៃគម្រោងទូលំទូលាយ ដែលផ្តល់ជាមូលដ្ឋានដល់ការការពារ ការគ្រប់គ្រង

និងការប្រើប្រាស់ទឹកសាបនិងទឹកប្រៃឱ្យមានចិរភាពស្មើភាព និងបម្រើផលប្រយោជន៍សាធារណៈឱ្យមានប្រសិទ្ធភាព ។ បច្ចុប្បន្ននេះប្រមាណ ២៧% នៃផ្ទៃដីស្រែសរុប មានប្រព័ន្ធធារាសាស្ត្រ ។ យោងតាមការប៉ាន់ស្មាន ប្រព័ន្ធធារាសាស្ត្រអាចមានសក្តានុពលសម្រាប់ផ្ទៃដីដាំដុះប្រហែល ៦៥% ។ ប្រសិនបើទីតាំងធារាសាស្ត្រអាចពង្រីកការផ្គត់ផ្គង់ទឹកបាន ផលិតភាពដីនឹងកើនឡើង ហើយកម្ពុជាអាចក្លាយជាជង្រុកស្រូវនៅក្នុងតំបន់ ។ ហេតុនេះ រាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់ខ្ពស់ក្នុងការស្តារ និងសាងសង់សំណង់ធារាសាស្ត្រ និងប្រព័ន្ធបង្ហូរទឹក ជាពិសេសនៅតំបន់ក្រីក្រខ្លាំង និងនៅតំបន់ព្រំដែន ។ សហគមន៍កសិករប្រើប្រាស់ទឹកមានចំនួនសមាជិកកើនឡើង ហើយការចូលរួមរបស់ស្ត្រីក៏ត្រូវបានពង្រឹងពង្រីកបន្ថែម ។

24. ផ្នែកសេវាកម្មបានរក្សាសមាមាត្រថេរក្នុងរង្វង់ ៣៨% និងអាចមានកំណើនតាមថ្លៃថេរ ចំនួន ៧,២% នៅឆ្នាំ ២០០៨ ។ វិស័យទេសចរណ៍នៅតែបន្តរីកចម្រើន ដែលកំណើនភ្ញៀវទេសចរបរទេសនឹងអាចកើនបានប្រមាណ ១០% នៅឆ្នាំ ២០០៨ នេះ ។ ការកើនឡើងយ៉ាងឆាប់រហ័សបានជំរុញឱ្យវិស័យទេសចរណ៍ ដែលមានលក្ខណៈជាប្រព័ន្ធ ក្លាយជាវិស័យទីពីរបន្ទាប់ពីវិស័យឧស្សាហកម្មកាត់ដេរ និងមានតួនាទីក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងការផ្តល់ឱកាសការងារជូនប្រជាពលរដ្ឋកម្ពុជាបានមួយចំនួនធំ ។ ជាការពិត ការគាំទ្រដល់វិស័យនេះ គឺបានមកដោយសារការខិតខំរបស់រាជរដ្ឋាភិបាល ក្នុងការពុះពារធ្វើឱ្យប្រសើរឡើង នូវហេដ្ឋារចនាសម្ព័ន្ធ រូបវ័ន្ត មានប្រព័ន្ធផ្លូវថ្នល់ អាកាសយានដ្ឋាន កំពង់ផែ ប្រព័ន្ធទឹកស្អាត និងអគ្គិសនី ក៏ដូចជា ការផ្តល់នូវបរិយាកាសសន្តិភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ដែលបានបង្កលក្ខណៈងាយស្រួលឱ្យមានការកើនឡើងនូវការស្នាក់នៅ និងការទស្សនាកំសាន្តរបស់ភ្ញៀវទេសចរ។

- ឯកឧត្តម លោកជំទាវ លោក លោកស្រី !

25. ផ្អែកលើកំណើនដូចបានរំលេចខាងលើនេះ ចំណូលរបស់ប្រជាជនម្នាក់ៗនៅឆ្នាំ ២០០៨ អាចមានចំនួនប្រមាណ ៦២៥ ដុល្លារ គឺបានកើនឡើងជាមធ្យមប្រមាណ ៩,៥% ក្នុងមួយឆ្នាំៗ ដោយគិតចាប់តាំងពីឆ្នាំ ១៩៩៩ មក ។ ការកើនឡើងនៃចំណូលនេះបានរួមចំណែកដល់ការសន្សំសម្រាប់បំពេញឱ្យតម្រូវការចាំបាច់ក្នុងការវិនិយោគសាធារណៈ និងឯកជនដែលមានតម្រូវការប្រមាណ ២២% នៃ ផសស ក្នុងមួយឆ្នាំៗ ដើម្បីសម្រេចកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំក្នុងល្បឿនជាមធ្យម ៩,៥% ។ រាជរដ្ឋាភិបាលបានគ្រប់គ្រងដោយហ្មត់ចត់និងប្រុងប្រយ័ត្នចំពោះស្ថានភាពអតិផរណា ដោយបានរក្សាឱ្យស្ថិតនៅក្នុងកម្រិតទាប ក្នុងរយៈពេលជាច្រើនឆ្នាំ ។ ប៉ុន្តែនៅឆ្នាំ ២០០៨ អតិផរណាប្រចាំឆ្នាំបានកើនឡើងលើសពី ២០% នៅឆមាសទីមួយ ដោយសារទទួលរងសម្ពាធពីការកើនឡើងតម្លៃប្រេង

ឥន្ធនៈ ការកើនឡើងតម្លៃទំនិញ និងម្ហូបអាហារ និងការធ្លាក់ថ្លៃនៃប្រាក់ដុល្លារ ។ សម្ពាធអតិផរណាបានស្រកចុះមកវិញនៅចុងឆមាសទីពីរឆ្នាំ២០០៨ នេះ ដែលតាមការប៉ាន់ប្រមាណធ្វើឱ្យអត្រាអតិផរណាជាមធ្យមក្នុងឆ្នាំ ២០០៨ មានប្រមាណ ១៥% ហើយនៅចុងឆ្នាំ ២០០៩ អត្រានេះនឹងអាចចុះបន្ថែមទៀត មកនៅត្រឹមកម្រិតតួលេខតែមួយខ្ទង់ក្នុងរង្វង់ ៧% ។ ជាមួយគ្នានេះ គោលនយោបាយរូបិយវត្ថុ និងអត្រាប្តូរប្រាក់ ក៏ត្រូវបានអនុវត្តក្នុងភាពប្រយ័ត្នប្រយែងក្នុងទិសដៅគ្រប់គ្រងអតិផរណា និង ធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។ ទុនបម្រុង របស់ជាតិបានកើនឡើងដល់ជាង ២ ពាន់លានដុល្លារ ដែលអាចធានាបានប្រមាណ ៣,៣ ខែ នៃការនាំចូលទំនិញ និងសេវាកម្មសម្រាប់ការប្រើប្រាស់ក្នុងស្រុក ។

26. បន្ទាប់ពីដាក់ឱ្យអនុវត្តនូវកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចំណូលថវិកាបានកើនឡើង ២៦% ជាមធ្យមក្នុងមួយឆ្នាំ ។ រាជរដ្ឋាភិបាលបានកែប្រែស្ថានភាពនៃការអនុវត្តថវិកា ***ពីភាពរ៉ាំរ៉ៃនៃឱនភាពសាច់ប្រាក់មក មានអតិរេកសាច់ប្រាក់*** ដោយធ្វើឱ្យថវិកាមាន ***ភាពជឿ ទុកចិត្តបាន*** ។ តាមរយៈការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់តាំងពីឆ្នាំ ២០០៤ មក ស្របពេលជាមួយគ្នា នឹងការអនុវត្តកំណែទម្រង់ធំៗដទៃទៀត ក្នុងកំឡុង ឆ្នាំ ២០០៤- ២០០៨ ចំណូលពន្ធគយ និងចំណូលពន្ធដារត្រូវបានប្រមូលតាមរយៈប្រព័ន្ធធនាគារ ការទូទាត់ពី រតនាគារទៅឱ្យអ្នកផ្គត់ផ្គង់ ត្រូវធ្វើឡើងតាមរយៈមូលប្បទានប័ត្របំណុលចាស់ៗ ត្រូវបានលុបបំបាត់ ដំណើរការលទ្ធកម្មមានសភាពប្រសើរជាងមុន ហើយនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៅតាមក្រសួង នីមួយៗត្រូវបានពង្រឹងផងដែរ។ ទន្ទឹមនេះ យើងបានពង្រឹងប្រសិទ្ធភាព និងសមធម៌ក្នុងការបែងចែកថវិកា ដោយបង្កើនចំណាយទៅលើការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច ជាពិសេសវិស័យហេដ្ឋារចនាសម្ព័ន្ធ រូបវ័ន្ត អប់រំ សុខាភិបាល និងកសិកម្ម និងបន្តបង្កើនវិចារណភាព និងប្រសិទ្ធភាពនៃចំណាយសាធារណៈ ដែលជាកត្តាយ៉ាងសំខាន់ អាចឱ្យយើងពង្រឹងបាននូវសេវាសាធារណៈ និងកាត់បន្ថយភាពក្រីក្ររបស់ ប្រជាជន ។

27. រាជរដ្ឋាភិបាលនឹងបន្តអនុវត្តឱ្យកាន់តែស៊ីជម្រៅថែមទៀតនូវ ***«កម្មវិធីកែទម្រង់ការគ្រប់-គ្រងហិរញ្ញវត្ថុសាធារណៈ»*** ជាពិសេសដំណាក់កាលទី ២ នៃកម្មវិធីនេះដែលត្រូវបានប្រកាសដាក់អនុវត្តជាផ្លូវការកាលពីម្សិលមិញនេះ ដើម្បីពង្រឹងប្រសិទ្ធភាពថវិកាជាតិដែលជាឧបករណ៍គន្លឹះក្នុងការអនុវត្តន៍គោលនយោបាយអភិវឌ្ឍរបស់រាជរដ្ឋាភិបាល ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងបន្តប្រកាន់ខ្ជាប់នូវវិន័យក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។ រាជរដ្ឋាភិបាលបន្តពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋយ៉ាងហ្មត់ចត់ស្រប

តាមច្បាប់និងបទប្បញ្ញត្តិជាធរមាន អនុវត្តប្រកបដោយប្រសិទ្ធភាព នូវវិធានការពង្រឹងការប្រមូលចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋគ្រប់ប្រភេទ ព្រមទាំង នឹងបន្តពង្រឹងប្រសិទ្ធភាពតម្លាភាព និងគណនេយ្យភាព នៃការគ្រប់គ្រងរបស់គ្រឹះស្ថានសាធារណៈនិងសហគ្រាសសាធារណៈ ។ រាជរដ្ឋាភិបាលប្តេជ្ញាគ្រប់គ្រងឱ្យមានប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាពនូវចំណូល ដែលបានមកពីការធ្វើអាជីវកម្មលើធនធានប៉េប្រេងកាត និងឧស្ម័ន ។

28. ទន្ទឹមនេះ រាជរដ្ឋាភិបាលបានអនុវត្តប្រកបដោយជោគជ័យនូវផែនការសកម្មភាពដែលបានដាក់ចេញក្នុង ***«ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០»*** ហើយបានធ្វើបច្ចុប្បន្ននីយកម្មឯកសារនេះឱ្យទៅជា ***« យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥»*** ជាមួយនឹងការប្តេជ្ញាចិត្តបន្តជំរុញអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍នេះ ឱ្យបានសម្រេចលទ្ធផលតាម ការរំពឹងទុក ។

-ឯកឧត្តម លោកជំទាវ លោក លោកស្រី !

29. រាជរដ្ឋាភិបាលបានបន្តការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសំខាន់ៗ និងបានបង្កើតនូវបរិស្ថានសមស្របដែលមានស្ថិរភាព និងអាចប៉ាន់ស្មានបាន ដើម្បីទាក់ទាញ និង លើកស្ទួយដល់វិនិយោគឯកជន ។ ជាការពិត ការកើនឡើងនៃចំណូលថវិកាជាតិបានអនុញ្ញាតឱ្យយើងអាចបង្វែរទុនវិនិយោគកាន់តែច្រើនថែមទៀត ទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសំខាន់ៗ រួមមានផ្លូវគមនាគមន៍ដឹកជញ្ជូននិងប្រព័ន្ធធារាសាស្ត្រ និងទៅលើការអភិវឌ្ឍន៍សង្គម និងធនធានមនុស្ស ដែលជាកត្តាដ៏ចាំបាច់សម្រាប់បង្កើតលក្ខខណ្ឌអំណោយផលដល់ការលើកស្ទួយ និងធានាចីរភាពនៃកំណើន ក៏ដូចជាអំណោយផលដល់ការបែងចែកផ្លែផ្កានៃកំណើននេះឱ្យបានទូលំទូលាយផងដែរ ។ ចាប់តាំងពីឆ្នាំ ១៩៩៩ មក រាជរដ្ឋាភិបាលបានបង្កើនចំណាយសន្សំកសន្ទាប់លើការកសាងហេដ្ឋារចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ច ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ យើងនៅតែពិនិត្យឃើញអំពីតម្រូវការនិងសក្តានុពលយ៉ាងធំធេងថែមទៀតរបស់កម្ពុជា នៅក្នុងការអភិវឌ្ឍន៍វិស័យកសិកម្ម និងធនធានទឹក រួមជាមួយនឹងសេចក្តីត្រូវការដ៏ច្រើនលើសលប់ថែមទៀត នៅក្នុងការកែលម្អ និងអភិវឌ្ឍប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ចដែលមានការពាក់ព័ន្ធ ក្នុងនោះមានបណ្តាញផ្លូវ-ស្ពាន ផ្លូវដែក ផ្លូវទឹក កំពង់ផែ និងអាកាសយានដ្ឋាន បណ្តាញផ្គត់ផ្គង់អគ្គិសនី និងទឹកស្អាតនៅតាមទីជនបទ សាលារៀននិងមន្ទីរសុខភាពសាធារណៈ។ល។ ដូច្នេះនៅក្នុងរយៈពេលមធ្យមខាងមុខ ការវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធទាំងអស់នេះ នៅតែបន្តស្ថិតនៅជាអាទិភាពដ៏ចម្បងរបស់រាជរដ្ឋាភិបាល

ហើយយើងខ្ញុំនឹងស្វាគមន៍យ៉ាងកក់ក្តៅចំពោះវិភាគទានដ៏សប្បុរសទាំងឡាយ ពីសំណាក់ដៃគូអភិវឌ្ឍន៍ទាំងអស់របស់យើង ។

30. រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងការអភិវឌ្ឍវិស័យឯកជនតាមរយៈការកែលម្អយន្តការស្ថាប័ន និងក្របខ័ណ្ឌគតិយុត្តិ និងនិយ័តកម្ម ។ រាជរដ្ឋាភិបាលបានរៀបចំពង្រឹងឡើងវិញ នូវយន្តការបញ្ជរតែមួយខាងផ្នែកវិនិយោគ និង សម្រេចបានជោគជ័យក្នុងការងារសម្រួលពាណិជ្ជកម្ម និង វិនិយោគ ក្នុងនោះ រួមមានការកាត់បន្ថយពេលវេលាក្នុងការសុំអនុញ្ញាតវិនិយោគ ការកំណត់តម្លៃសេវាកម្មសាធារណៈឱ្យបានច្បាស់លាស់ ការកាត់បន្ថយតម្រូវការខាងផ្នែកវិញ្ញាបនបត្រផលិតកម្ម និងការចុះត្រួតពិនិត្យធ្វើអធិការកិច្ចនានា ការកាត់បន្ថយតម្រូវការក្នុងការសុំអាជ្ញាប័ណ្ណផ្សេងៗ ការបំព្រួញបែបបទអន្តរស្ថាប័ន ក្នុងការត្រួតពិនិត្យទំនិញ ការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងហានិភ័យ និងស្វ័យប្រវត្តិកម្មការងារគយ ការកាត់បន្ថយចំណាយក្រៅផ្លូវការក្នុងការរត់ការបំពេញបែបបទរដ្ឋបាល និងការដាក់ចេញនូវបទដ្ឋានគតិយុត្តិ និងយន្តការស្ថាប័នសម្រាប់អភិវឌ្ឍ និងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ។ ល ។

31. រាជរដ្ឋាភិបាលចាត់ទុកវិស័យឯកជន ជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច ហើយរាជ-រដ្ឋាភិបាលជាអ្នករៀបចំយុទ្ធសាស្ត្រ ដើម្បីបង្កើតបរិស្ថានធុរកិច្ចឱ្យកាន់តែប្រសើរសម្រាប់វិស័យឯកជន និងជាអ្នកគ្រប់គ្រងការអភិវឌ្ឍន៍ ។ លើមូលដ្ឋាននៃទស្សនវិជ្ជានេះ រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យមានវិនិយោគឯកជនលើវិស័យហេដ្ឋារចនាសម្ព័ន្ធ តាមរូបភាព ***«សាងសង់- ប្រតិបត្តិការ- ផ្ទេរ»*** (BOT) ដែលធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនមានភាពកាន់តែប្រសើរឡើង ។ ជាក់ស្តែង គិតមកដល់ឆ្នាំ ២០០៧ រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យក្រុមហ៊ុនចំនួន ១៧ វិនិយោគ លើហេដ្ឋារចនាសម្ព័ន្ធតាមរូបភាព ***«សាងសង់-ប្រតិបត្តិការ- ផ្ទេរ»*** ដែលមានទុនចុះបញ្ជីចំនួន ៧៧,៥ លាន ដុល្លារ និងទុនអចលនទ្រព្យចំនួន ៥៨៨ លានដុល្លារ ។

32. ទន្ទឹមនេះដែរ រាជរដ្ឋាភិបាលក៏សម្រេចបាននូវក្របខ័ណ្ឌគតិយុត្តិចាំបាច់ជាច្រើន សម្រាប់គាំទ្រការអភិវឌ្ឍវិស័យឯកជន ក្នុងនោះ វេទិការដ្ឋាភិបាល-វិស័យឯកជនបានក្លាយជាយន្តការមួយដ៏មានប្រសិទ្ធភាព ក្នុងការដោះស្រាយបញ្ហាទាំងឡាយដែលជាកង្វល់រួមរបស់រាជរដ្ឋាភិបាល និងដៃគូវិស័យឯកជន ។ កំណែទម្រង់កិច្ចសម្រួលពាណិជ្ជកម្មបានកាត់បន្ថយតម្រូវការផ្នែកឯកសារ ដែលជាជំហានវិជ្ជមានមួយយ៉ាងសំខាន់សម្រាប់ជំរុញ ធុរកិច្ចវិស័យឯកជន ជាពិសេសក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដំណើរការចុះបញ្ជីក្រុមហ៊ុនត្រូវបានធ្វើឱ្យកាន់តែសាមញ្ញ ។ ចំណាយសម្រាប់ការចុះបញ្ជីបានថយពី ៦៣០ ដុល្លារ នៅឆ្នាំ ២០០៤ មកត្រឹម ១១៧ ដុល្លារ នាពេលបច្ចុប្បន្ន ។ សេវា

«ច្រកចេញ-ចូលតែមួយ» ត្រូវបានបង្កើត និងដំណើរការនៅតំបន់សេដ្ឋកិច្ចពិសេស ដូចជានៅ ***បាវិត*** ជាដើម ។ ការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធ ***«រដ្ឋបាលតែមួយ»*** និងសេវា ***«ច្រកចេញ-ចូលតែមួយ»*** បាននាំមកនូវផលប្រយោជន៍សម្រាប់ការអភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម ។ រាជរដ្ឋាភិបាល បានកាត់បន្ថយតម្រូវការអប្បរមា សម្រាប់ការចុះបញ្ជីទុនរបស់សហគ្រាស ធុនតូច និងមធ្យម ពី ៥.០០០ ដុល្លារ មកត្រឹម ១.០០០ ដុល្លារ ហើយចំណាយលើ ការចុះបញ្ជី ក្រុមហ៊ុនត្រឹមតែ ១៧៧ ដុល្លារ ។ អគ្គនាយកដ្ឋានពន្ធដារបានកែលម្អប្រព័ន្ធរបាយការណ៍ឱ្យមាន លក្ខណៈកាន់តែសាមញ្ញ សម្រាប់ជួយដល់ការអភិវឌ្ឍន៍សហគ្រាសធុនតូច និង មធ្យម ។

33. ព្រមជាមួយនេះ រាជរដ្ឋាភិបាលបានខិតខំជំរុញការអភិវឌ្ឍវិស័យព័ត៌មានវិទ្យា និង ទូរគមនាគមន៍ប្រកបដោយគុណភាពខ្ពស់ ស្របតាមស្តង់ដារអន្តរជាតិ មានថ្លៃថោកសមរម្យ និងមាន សេវាទំនើបគ្របដណ្តប់ទូទាំងប្រទេស ។ ស្របតាម ***យុទ្ធសាស្ត្រចតុកោណ*** របស់រាជរដ្ឋាភិបាល គម្រោងអភិវឌ្ឍន៍ផ្នែកព័ត៌មានវិទ្យា និងទូរគមនាគមន៍ធំៗពីរត្រូវបានអនុវត្ត គឺប្រព័ន្ធព័ត៌មានវិទ្យា រដ្ឋបាល និងរដ្ឋាភិបាលអេឡិចត្រូនិច *(E-government)* ។ គោលដៅចំបង គឺទាមទារការខិត ចូលឱ្យកាន់តែជិតរវាងប្រជាពលរដ្ឋ អាជីវករ និង រដ្ឋាភិបាល ។

-ឯកឧត្តម លោកជំទាវ លោក លោកស្រី

34. ការអភិវឌ្ឍន៍វិស័យអប់រំបានឈានចូលទៅក្នុងដំណាក់កាលមួយថ្មីទៀត ដោយផ្តោតការ យកចិត្តទុកដាក់ទៅលើការពង្រឹងមូលដ្ឋានអប់រំ និងគុណភាពសិក្សានៅក្នុងក្របខ័ណ្ឌការអភិវឌ្ឍន៍ សេដ្ឋកិច្ចជាតិ ដែលមានលក្ខណៈជាប្រព័ន្ធដ៏ទូលំទូលាយ ។ ជាចក្ខុវិស័យសម្រាប់រយៈពេលវែង រាជរដ្ឋាភិបាលបានផ្សារភ្ជាប់យុទ្ធសាស្ត្រអប់រំ ទៅនឹងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន តាមរយៈការធ្វើសមាហរណកម្មផែនការហិរញ្ញប្បទានវិស័យអប់រំជាមួយនឹងផែនការ និងការគ្រប់គ្រង ចំណាយសាធារណៈ ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គ្រឹះស្ថានសិក្សាជាច្រើនត្រូវបាន បង្កើតឡើង គុណភាពនៃការសិក្សារបស់សិស្ស-និស្សិត និងជីវភាពរបស់គ្រូបង្រៀនត្រូវបានផ្តល់ អាទិភាព និងផ្តោតការយកចិត្តទុកដាក់ទៅតាមលទ្ធភាពនៃកំណើនសេដ្ឋកិច្ច ។ ទន្ទឹមនេះ រាជរដ្ឋាភិបាល នីតិកាលទី ៣ បានប្រកាសផ្សព្វផ្សាយ ***ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៦-២០១០*** ដែលជា ផ្នែកមួយនៃ***យុទ្ធសាស្ត្រចតុកោណ*** និង***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០*** របស់រាជរដ្ឋាភិបាល ហើយដែលបានផ្តោតការយកចិត្តទុកដាក់ទៅលើការធានាថា កុមារ និង

យុវជនកម្ពុជាទាំងអស់មានកាលានុវត្តភាពស្មើៗគ្នា ក្នុងការទទួលការអប់រំមូលដ្ឋាននៅក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការ-នយោបាយ ដើមកំណើត និងឋានៈនៅក្នុងសង្គមឡើយ ។ ក្នុងផ្នែកសីលធម៌រស់នៅផែនការយុទ្ធសាស្ត្រនេះ បានផ្សារភ្ជាប់ទៅនឹងការអប់រំនៃវប្បធម៌ សន្តិភាព ការគោរពសិទ្ធិមនុស្ស ការគោរពគោលការណ៍ច្បាប់ គោលការណ៍សេរីភាព ប្រជាធិបតេយ្យ និងយុត្តិធម៌ ដោយប្រឆាំងនឹងអំពើហឹង្សា ប្រឆាំងនឹងការប្រើប្រាស់គ្រឿងញៀន ការជួញដូរកុមារ និងស្ត្រី និងការរើសអើងគ្រប់ប្រភេទក្នុងសង្គម ។ ប្រការទាំងអស់នេះ បញ្ជាក់ឱ្យឃើញច្បាស់ថា ***«ការអប់រំ គឺសម្រាប់ទាំងអស់គ្នា ហើយទាំងអស់គ្នា គឺសម្រាប់ការអប់រំ»*** ដែលជាការអនុវត្តន៍ជំពូកទី ៦ នៃរដ្ឋធម្មនុញ្ញស្តីពីសិទ្ធិស្មើភាព គ្នារបស់ប្រជាពលរដ្ឋទាំងអស់ ។

35. ក្នុងការអនុវត្តន៍យុទ្ធសាស្ត្រនេះ កន្លងមកតាមរយៈការធានាសមធម៌ក្នុងការអប់រំមូលដ្ឋានរយៈពេល ៩ ឆ្នាំសម្រាប់កុមារគ្រប់រូប រាជរដ្ឋាភិបាលសម្រេចបាននូវវឌ្ឍនភាពគួរជាទីមោទនៈ ។ ចំនួនសាលារៀនបានកើនឡើង ៣០% ពី ចំនួន ៦.៩៦៣ នៅឆ្នាំសិក្សា ២០០៣-២០០៤ ដល់ ចំនួន ៩.០១៨ នៅឆ្នាំសិក្សា ២០០៦- ២០០៧។ អត្រាចុះឈ្មោះចូលរៀនបានកើនឡើងនៅគ្រប់កម្រិតសិក្សា ។ អាហារូបករណ៍សម្រាប់សិស្សក្រីក្រ ថ្នាក់មធ្យមសិក្សាបានកើនដល់ ចំនួន ៤៥.៧៥៤ នាក់ ក្នុងនោះ ៦៣,២% ជានារី ។ បុគ្គលិក បង្រៀនបានកើនឡើងពី ៧៣.៦៤២ នាក់ នៅក្នុងឆ្នាំសិក្សា ២០០៣-២០០៤ ដល់ ៧៨.៦០៦ នាក់ នៅក្នុងឆ្នាំសិក្សា ២០០៦-២០០៧ ។

36. រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវនយោបាយឯកជនូបនីយកម្មតាំងពីទសវត្សរ៍ឆ្នាំ ៩០ ធ្វើឱ្យគ្រឹះស្ថានមធ្យមសិក្សា និងគ្រឹះស្ថានឧត្តមសិក្សាជាច្រើនបានកើតឡើងយ៉ាងឆាប់រហ័ស ។ បច្ចុប្បន្នមានគ្រឹះស្ថានឧត្តម-សិក្សាចំនួន ៦៦ ដែលក្នុងនោះ ២៤ គ្រឹះស្ថានជាកម្មសិទ្ធរបស់រដ្ឋ និង ៤២ គ្រឹះស្ថានទៀតជារបស់ឯកជន ។ ទន្ទឹមនឹងនេះដែរ ថវិកាសម្រាប់វិស័យអប់រំបានកើនយ៉ាងច្រើន ។ ថវិកាចរន្តសម្រាប់វិស័យអប់រំក្នុងឆ្នាំ ២០០៧ កើនឡើងជិតពីរដង ធៀបទៅនឹងឆ្នាំ ២០០៣ គឺពីចំនួន ៣០០ ទៅ ៥៤៦ ពាន់ លានរៀល ឬបាន កើនឡើងពី ១៧,១% ទៅ ១៩,២% នៃថវិកាចរន្តសរុប ។

37. ក្នុងវិស័យសុខាភិបាល រាជរដ្ឋាភិបាលបានផ្តល់អាទិភាពខ្ពស់ទៅលើការការពារ និងទប់ស្កាត់ទាន់ពេលវេលាដល់ជម្ងឺរាតត្បាតផ្សេងៗ ការថែរក្សាសុខភាព និងអាហារូបត្ថម្ភរបស់ប្រជាពលរដ្ឋកម្ពុជា និងបានចាត់ទុកប្រជាពលរដ្ឋមាន សុខភាពល្អ ជាកត្តាដ៏ចម្បងសម្រាប់ការអភិវឌ្ឍ ធនធានមនុស្ស និងវឌ្ឍនភាពសង្គម និងសេដ្ឋកិច្ចប្រកបដោយចិរភាព ។ រាជរដ្ឋាភិបាលបាន លើកស្ទួយ

សុខុមាលភាពប្រជាពលរដ្ឋទូទៅ ពិសេសប្រជាពលរដ្ឋក្រីក្រ ស្ត្រី និងកុមារ តាមរយៈ ការជួយគាំទ្រក្នុងការងារអភិវឌ្ឍន៍សេវាសុខាភិបាល ទាំងផ្នែកការពារ និងព្យាបាលដែលមានតម្លៃទាបគុណភាពសមរម្យ និងប្រើប្រាស់បានទាំងអស់គ្នា ក៏ដូចជាជួយពង្រឹងសមត្ថភាពរបស់ស្ថាប័ន លើការរៀបចំផែនការហិរញ្ញប្បទាន ព្រមទាំងអនុវត្តកម្មវិធីនយោបាយជាយុទ្ធសាស្ត្រ និងគ្រប់គ្រងធនធានឱ្យមានប្រសិទ្ធភាព ។

38. ជាលទ្ធផល អត្រាស្លាប់របស់ទារកបានថយចុះពី ៩៥ មកត្រឹម ៦៦ ក្នុង ១.០០០ កំណើតនៅក្នុងរវាងឆ្នាំ ២០០០- ២០០៥ ។ អត្រាស្លាប់របស់កុមារក្រោមអាយុ ៥ ឆ្នាំ ក៏បានធ្លាក់ចុះ នៅក្នុងកំឡុងពេលដូចគ្នានេះដែរ ។ អត្រាមរណមាតា បានធ្លាក់ចុះពី ៤៧២ មកត្រឹម ៤៣៧ ក្នុង ១០០.០០០ កំណើត ។

39. ស្ត្រីត្រូវបានចាត់ទុកថា ជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និង សង្គមជាតិយើង ។ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែង ដើម្បីជួយលើកស្ទួយឋានៈរបស់ស្ត្រីតាមរយៈការបន្តអនុវត្តនូវផែនការ យុទ្ធសាស្ត្រ ***«នារីរតនៈ»*** ឬ ***ស្ត្រី*** គឺ ***ជាត្បូងមានតម្លៃ*** ក្នុងគោលបំណងផ្តល់ជូនស្ត្រីខ្មែរនូវតម្លៃ និងក្តីសង្ឃឹមក្នុងជីវិត និងដែលផ្តោតលើបញ្ហាយេនឌ័រក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ រាជរដ្ឋាភិបាលផ្តល់អាទិភាពខ្ពស់ទៅការលើកកម្ពស់តួនាទី និងស្ថានភាពសង្គមរបស់ស្ត្រី ដោយជំរុញការអនុវត្តន៍យុទ្ធសាស្ត្រយេនឌ័រ *(Gender Mainstreaming)* ដែលផ្តោតលើការកសាងសមត្ថភាពរបស់ស្ត្រី ការលើកកម្ពស់លទ្ធភាពរបស់ស្ត្រីក្នុងវិស័យអប់រំ សុខាភិបាលនិងធនធានសេដ្ឋកិច្ច ការផ្លាស់ប្តូរឥរិយាបថសង្គមជាអវិជ្ជមានចំពោះស្ត្រី និងការបង្កើនការចូលរួមរបស់ស្ត្រីក្នុងគ្រប់កិច្ចសាធារណៈព្រមទាំងការធានាសិទ្ធិ ដើម្បីឱ្យស្ត្រីមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចូលរួមយ៉ាងសកម្ម និងដោយស្មើភាពក្នុងដំណើរការកសាងប្រទេសជាតិ ។ រាជរដ្ឋាភិបាលបានអនុវត្តយ៉ាងហ្មឹងម៉ាត់នូវផែនការ និងយុទ្ធសាស្ត្រនានា ដើម្បីធានាឱ្យស្ត្រីគ្រប់រូបមានសិទ្ធិក្នុងការទទួលបានការថែទាំសុខភាព តាមរយៈការបង្កើតក្រុមការងារសកម្មភាពសហគមន៍ និងមជ្ឈមណ្ឌលសម្រាប់ផ្តល់សេវាសុខភាព ព្រមទាំងការណែនាំពីការថែរក្សា និងបង្ការជម្ងឺផ្សេងៗជាដើម ។

40. ម្យ៉ាងទៀតការលើកកម្ពស់ស្ថានភាពសេដ្ឋកិច្ចសម្រាប់ស្ត្រី ជាពិសេសស្ត្រីក្រីក្រគ្មានការងារធ្វើ និងពិការ គឺជាគោលដៅចំបងនៃយុទ្ធសាស្ត្រយេនឌ័រ ។ មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីត្រូវបានពង្រឹងក្នុងខេត្តចំនួនប្រាំបី ដើម្បីបណ្តុះបណ្តាលស្ត្រីក្នុងតំបន់ទាំងនោះ ដោយផ្តោតលើការបណ្តុះបណ្តាលវិជ្ជាជីវៈផ្អែកលើតម្រូវការរបស់ទីផ្សារនិងភាពជាសហគ្រិនខ្នាតតូចជាដើម ។ សេវាអភិវឌ្ឍន៍អាជីវកម្ម

(BDS) ត្រូវបានបង្កើតឡើងសម្រាប់ស្ត្រីនៅជនបទ និងសហគ្រិនខ្នាតតូចសម្រាប់ស្ត្រី។ រាជរដ្ឋាភិបាលក៏បានត្រួតពិនិត្យយ៉ាងហ្មត់ចត់នូវការអនុវត្តន៍ច្បាប់ការងារ និងបទប្បញ្ញត្តិពាក់ព័ន្ធសម្រាប់ការពារស្ត្រីក្នុងការងារ ។

41. ព្រមជាមួយនេះ ដើម្បីទប់ស្កាត់អំពើហិង្សាទៅលើស្ត្រី ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះត្រូវបានអនុម័តនៅក្នុងឆ្នាំ ២០០៥ ។ ច្បាប់នេះ ផ្តល់ការការពារស្របច្បាប់ និងមានប្រសិទ្ធភាព និងទាន់ពេលវេលា សម្រាប់ជនរងគ្រោះដែលភាគច្រើនជាស្ត្រី និងកុមារ ។ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា នៅក្នុងការប្រឆាំងនឹងការជួញដូរស្ត្រី និងកុមារ ចាប់តាំងពីឆ្នាំ ២០០៦ មកម្ល៉េះ ។ ច្បាប់ថ្មីប្រឆាំងនឹងការជួញដូរនេះ ក៏ត្រូវបានអនុម័តក្នុងឆ្នាំ ២០០៨ នេះដែរ ។ ផែនការជាតិទប់ស្កាត់អំពើហិង្សាទៅលើស្ត្រីកំពុងត្រូវបានរៀបចំ ដើម្បីលើកកម្ពស់ការផ្សព្វផ្សាយ ការយល់ដឹងជាសាធារណៈ និងការអនុវត្តន៍ច្បាប់ពាក់ព័ន្ធនឹងស្ត្រី ។

- ឯកឧត្តម លោកជំទាវ លោក លោកស្រី !

42. ទន្ទឹមនឹងទទួលបានជោគជ័យដែលសម្រេចបានខាងលើនេះ កម្ពុជាក៏កំពុងជួបនឹងបញ្ហាប្រឈមមួយចំនួនផងដែរ ។ ជាក់ស្តែងគុណភាព ប្រសិទ្ធភាព និងការផ្តល់សេវាសាធារណៈនៅមានកម្រិតមិនទាន់អាចឆ្លើយតបបានទៅនឹងតម្រូវការចាំបាច់ជាក់ស្តែងនៅឡើយ ។ ការផ្តល់សេវាសុខាភិបាលសាធារណៈប្រកបដោយគុណភាពនៅមានកម្រិត ។ សេវាថែទាំសុខភាព និងអនាម័យជនបទរួមទាំងការផ្គត់ផ្គង់ទឹកស្អាតជនបទសម្រេចបានក្នុងកម្រិតទាបនៅឡើយ បើប្រៀបធៀបទៅនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។ ដោយឡែកស្ថាប័នតុលាការនៅមិនទាន់អាចទទួលបាន នូវជំនឿទុកចិត្តពេញលេញពីសំណាក់មហាជន ការងារកសាងក្របខ័ណ្ឌច្បាប់ នៅមិនទាន់មានភាពគ្រប់ជ្រុងជ្រោយ ហើយការអនុវត្តន៍ច្បាប់ក៏នៅមិនទាន់បានល្អប្រសើរពេញលេញនៅឡើយ ។

43. មូលដ្ឋាននៃកំណើនសេដ្ឋកិច្ច ដែលពឹងផ្អែកជាសំខាន់លើសសរទ្រូងបួន គឺវិស័យកាត់ដេរ ទេសចរណ៍ សំណង់ និងកសិកម្មនៅមានលក្ខណៈតូចចង្អៀតនៅឡើយ ។ វិស័យកាត់ដេរ និងទេសចរណ៍ងាយរងនូវហានិភ័យពីខាងក្រៅ ។ វិស័យកសិកម្មមានប្រមាណ ៣០% នៃ ផសស និងជាមូលដ្ឋានបង្កើតការងារសម្រាប់ប្រជាជនជាង ៦០% មិនទាន់ប្រើឱ្យអស់នូវសក្តានុពលរបស់ខ្លួននៅឡើយ ។

44. អតុល្យភាពសេដ្ឋកិច្ច និងវិបត្តិហិរញ្ញវត្ថុពិភពលោកនាពេលបច្ចុប្បន្ននេះ បានធ្វើឱ្យស្ថានភាពហិរញ្ញវត្ថុរបស់ប្រទេសទាំងអស់នៅលើពិភពលោកជួបប្រទះបញ្ហាប្រឈមដ៏ធំមួយ ។ ភាពរឹងស្លួតនៃឥណទាន នៅក្នុងប្រទេសរបស់វិនិយោគិននឹងបណ្តាលឱ្យមានការលំបាកកាន់តែខ្លាំងថែមទៀត

ចំពោះការវិនិយោគ ហើយដែលកត្តានេះធ្វើឱ្យពួកគេជួបការលំបាកក្នុងការផ្គត់ផ្គង់ហិរញ្ញវត្ថុដល់គម្រោងទាំងឡាយក្នុងប្រទេសរបស់យើង ។ ការធ្លាក់ចុះ នៃកំណើនសេដ្ឋកិច្ចរបស់បណ្ដាប្រទេសអភិវឌ្ឍន៍ បានធ្វើឱ្យប៉ះពាល់ដោយផ្ទាល់ដល់ទីផ្សារនាំចេញរបស់កម្ពុជា ពីព្រោះតម្រូវការទំនិញបានធ្លាក់ចុះ ។

45. គម្លាតនៃប្រាក់ចំណូលរវាងអ្នកមាន និងអ្នកក្ររវាងទីក្រុង តំបន់ទីប្រជុំជន និងតំបន់ជនបទ ការប្រមូលផ្ដុំដីធ្លី និងចំនួនពលរដ្ឋដែលគ្មានដី មាននិន្នាការកើនឡើង ។ ម៉្យាងវិញទៀត ដីមួយចំនួនធំដែលរដ្ឋបានផ្ដល់ជាសម្បទានសេដ្ឋកិច្ចមិនទាន់ត្រូវបានប្រើប្រាស់ឱ្យចំគោលដៅ និងប្រកបដោយប្រសិទ្ធភាពនៅឡើយ ។ ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីដោយខុសច្បាប់ និងបទប្បញ្ញត្តិ ការរំលោភយកដីរដ្ឋ ការកាប់រានទន្ទ្រានដីព្រៃក្នុងតំបន់ការពារធម្មជាតិទៅធ្វើជាកម្មសិទ្ធិឯកជន និងការកាប់ឈើដោយខុសច្បាប់នៅតែមានជាអន្លើៗនៅឡើយ ។ ទន្ទឹមនេះ ភាពក្រីក្រ និងបាតុភូតចំណាកស្រុកទៅរានដីថ្មីល្មើសនឹងច្បាប់អនុញ្ញាត បានធ្វើឱ្យធនធានធម្មជាតិរងសម្ពាធនៃការបំផ្លាញយ៉ាងខ្លាំង ដែលទាមទារឱ្យរាជរដ្ឋាភិបាលចាត់វិធានការតឹងរ៉ឹងដើម្បីដោះស្រាយ ។

46. ការស្ដារ ការកសាងឡើងវិញ ការជួសជុល ការថែទាំ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលក្នុងនោះរួមមាន ផ្លូវជាតិ ផ្លូវខេត្ត ផ្លូវលំជនបទ ផ្លូវដែក អាកាសយានដ្ឋាន កំពង់ផែ ប្រព័ន្ធទឹកស្អាត និងអគ្គិសនីឱ្យបានជាប្រព័ន្ធ និងមានចីរភាពនៅតែជាបញ្ហាប្រឈមរបស់យើងនៅឡើយ ។

47. ប្រព័ន្ធធារាសាស្ត្រមិនទាន់ត្រូវបានអភិវឌ្ឍគ្រប់គ្រាន់តាមសេចក្ដីត្រូវការ និងមិនត្រូវបានប្រើប្រាស់ឱ្យអស់សក្ដានុពលនៅឡើយ ដែលតម្រូវឱ្យមានការបង្កើនប្រសិទ្ធភាពគ្រប់គ្រង និងវិនិយោគបន្ថែមទៀត ។ ចំណែកឯហិរញ្ញប្បទាន ការគ្រប់គ្រង និងបច្ចេកវិទ្យា ក៏កំពុងស្ថិតនៅជាបញ្ហាប្រឈមដ៏ស្រួចស្រាល់របស់សហគ្រាសធុនតូច និងមធ្យម ។

48. អគ្គិសនីនៅមានថ្លៃខ្ពស់ធៀបនឹងប្រទេសជិតខាង ដែលជាឧបសគ្គដ៏ធំមួយសម្រាប់ពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា ក៏ដូចជាសម្រាប់ទាក់ទាញការវិនិយោគ និងលើកកម្ពស់ជីវភាពរបស់ប្រជាជន ។ វិសាលភាពនៃការប្រើប្រាស់អគ្គិសនីនៅជនបទ ក៏នៅមានកម្រិតទាបនៅឡើយ ។

49. ជារួម គុណភាពអប់រំនៅមានកម្រិតទាប ទាំងនៅកម្រិត បឋមសិក្សា មធ្យមសិក្សា និងឧត្ដមសិក្សា ។ ការផលិត និងការជួញដូរគ្រឿងញៀនបានក្លាយជាបញ្ហាសង្គមមួយ ដែលអាចប៉ះពាល់ដល់សុខុមាលភាពរបស់យុវជននិងយុវនារីកម្ពុជា ទាំងនៅពេលបច្ចុប្បន្ន ទាំងនៅពេលអនាគត ។ ការទទួលបាននូវការអប់រំតិចតួច អំពើហិង្សាក្នុងគ្រួសារ និងអំពើជួញដូរមនុស្ស គឺជាកត្តាដែលធ្វើឱ្យស្ត្រីមិនអាចប្រើប្រាស់អស់នូវសក្ដានុពលរបស់ខ្លួន ដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍សង្គម-

សេដ្ឋកិច្ច ។ សមត្ថភាពស្ថាប័នរបស់យើងនៅមានកម្រិតនៅឡើយ ដោយសារប្រាក់បៀវត្ស និងការលើកទឹកចិត្តរបស់មន្ត្រីរាជការនៅទាប កិច្ចសហប្រតិបត្តិការអន្តរស្ថាប័ននៅមានកម្រិតលិខិតបទដ្ឋានមួយចំនួននៅមានចន្លោះប្រហោង និងធនធានសម្រាប់អនុវត្តគោលនយោបាយដែលបានដាក់ចេញ ក៏នៅមានការខ្វះខាត ។

- ឯកឧត្តម លោកជំទាវ លោក លោកស្រី !

50. អ្វីដែលខ្ញុំបានលើកឡើង និងគូសបញ្ជាក់ខាងលើពាក់ព័ន្ធនឹងការវាយតម្លៃអំពីសមិទ្ធផល បញ្ហាប្រឈម និងវិធានការគោលនយោបាយជាយុទ្ធសាស្ត្ររបស់យើង សម្រាប់ការត្រួសត្រាយបន្តដំណើរទៅមុខទៀតក្នុងជំហានកាន់តែស្វាហាប់ជាងមុន គឺមានអធិប្បាយលម្អិតនៅក្នុង**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ២** ដែលខ្ញុំរំពឹងថា ដៃគូអភិវឌ្ឍន៍ទាំងអស់ពិតជាបានទទួលឯកសារនេះរួចអស់ហើយ ។ បន្ថែមលើនេះទៀត រាជរដ្ឋាភិបាលក៏បានរៀបចំ និងផ្សព្វផ្សាយនៅក្នុងកិច្ចប្រជុំនេះផងដែរ នូវរបាយការណ៍ពាក់កណ្តាលអាណត្តិនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ សម្រាប់ឆ្នាំ ២០០៨ ដែលជាការវាយតម្លៃបូកសរុបប្រហាក់ប្រហែលគ្នាដែរ អំពីការងារដែលយើងសម្រេចបានក្នុងរយៈពេលជាងពីរឆ្នាំចុងក្រោយនេះ ព្រមទាំងឆ្លុះបញ្ចាំងអំពីបញ្ហាប្រឈម និងយុទ្ធសាស្ត្របន្តដំណើរទៅមុខរបស់យើង ជាមួយនឹងការប្តេជ្ញាចិត្តដ៏មោះមុតឥតរាថយ ក្នុងការជំនះឱ្យខាងតែបាននូវបញ្ហាប្រឈមទាំងឡាយនេះ ដើម្បីបុព្វហេតុនៃការកាត់បន្ថយ ភាពក្រីក្រ និងការអភិវឌ្ឍន៍ ។ ដូច្នេះខ្ញុំរំពឹងថា អង្គប្រជុំរបស់យើងក្នុងរយៈពេលពីរថ្ងៃនេះ នឹងផ្តល់ពេលវេលាសមរម្យសម្រាប់ការពិភាក្សាលើបណ្តាសមិទ្ធផល ក៏ដូចជាការខ្វះខាត និងបញ្ហាប្រឈម ទាំងឡាយដែលយើងទាំងអស់គ្នាកំពុងតែជួបប្រទះនេះ ដើម្បីរកវិធីបង្កើនល្បឿននៃដំណើរទៅមុខរបស់កម្ពុជាឆ្ពោះទៅរកវឌ្ឍនភាព និងវិបុលភាពដ៏រុងរឿង ។

51. នៅក្នុងបរិការណ៍នេះ ច្បាស់ណាស់ថា ***«ភាពជាដៃគូ»*** គឺជាប្រធានបទដ៏សំខាន់មួយទៀតនៅក្នុងវេទិការយៈពេល ២ថ្ងៃរបស់យើងនេះ ។ ការធ្វើការរួមគ្នា ការបង្កើនទំនុកចិត្ត និង ការយល់គ្នាទៅវិញទៅមក គឺជាកត្តាកំណត់ដ៏សំខាន់ដើម្បីឈានទៅសម្រេចឱ្យបាននូវគោលដៅនៃ **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ២** ។ ដូច្នេះនៅពេលដែលយើងកៀរគរធនធាន និងតម្រង់ការប្រើប្រាស់ធនធានទាំងនោះសម្រាប់អនុវត្តសកម្មភាពអាទិភាពនានា យើងក៏ត្រូវធានាដែរថាភាពជាដៃគូរវាងគ្រប់តួអង្គដែលមានការពាក់ព័ន្ធទាំងអស់ នៅក្នុងទំនាក់ទំនងដើម្បីការគាំទ្រដល់

កិច្ចអភិវឌ្ឍន៍ ក៏មានវឌ្ឍនភាពទៅមុខប្រកបដោយប្រសិទ្ធភាពផងដែរ ។ នេះគឺជាស្មារតីនៃការប្តេជ្ញា ដែលរាជរដ្ឋាភិបាលបានកំណត់យ៉ាងច្បាស់លាស់នៅក្នុង **យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ២** តាមរយៈការអនុវត្តន៍គោលការណ៍នានា ដែលមានចែងក្នុង ***«ផែនការសកម្មភាពទីក្រុងអាក្រា»*** ដែលប្រធានស្ថាប័ននៃដៃគូអភិវឌ្ឍន៍ និងប្រទេសជាដៃគូបានព្រមព្រៀងគ្នាក្នុងកម្រិតអន្តរជាតិ នៅវេទិកាកំពូលលើកទី ៣ កាលពីខែកញ្ញា កន្លងទៅនេះ ដើម្បីពង្រឹងភាពជាម្ចាស់ភាពជាអ្នកដឹកនាំ ភាពជាដៃគូ និងតម្លាភាព ជាមួយដៃគូអភិវឌ្ឍន៍ទាំងអស់ ព្រមទាំង ពង្រឹងការគ្រប់គ្រងដោយផ្តោតលើលទ្ធផល ។ ក្នុងបរិការណ៍នេះ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះឯកឧត្តម **ឈៀង យ៉ាណារ៉ា** ដែលបានដឹកនាំការរៀបចំ

«របាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា »

ដែលក្នុងរបាយការណ៍នេះបានរំលេចយ៉ាងច្បាស់អំពីបញ្ហាប្រឈម ដែលកម្ពុជាកំពុងជួបប្រទះក្នុងការប្រើប្រាស់នូវធនធានដើម្បីសម្រេចកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផលនេះ ។

52. ខ្ញុំពិតជាមានសេចក្តីសោមនស្ស ដោយសង្កេតឃើញដៃគូរបស់យើងជាច្រើន បានចូលរួមក្នុងវេទិកាថ្ងៃនេះ ។ រាជរដ្ឋាភិបាលសូមស្វាគមន៍ និងវាយតម្លៃខ្ពស់ចំពោះទស្សនៈដ៏សម្បូរបែបស្តីពីកិច្ចអភិវឌ្ឍ ដែលដៃគូរបស់យើងអាចផ្តល់ជាវិភាគទានដល់កម្ពុជា សម្រាប់ជាទុនក្នុងការបន្តពង្រឹងដំណើរការអភិវឌ្ឍន៍កម្ពុជា ឱ្យមានភាពកាន់តែរឹងមាំឡើងថែមទៀត ។ កិច្ចប្រឹងប្រែងពង្រឹងទំនាក់-ទំនង និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងគ្រប់រូបភាព ជាមួយនឹងបណ្តាដៃគូទាំងអស់កាន់តែមានសារៈសំខាន់ខ្លាំងឡើងទៀតក្នុងពេលបច្ចុប្បន្ន ដែលកម្ពុជាកំពុងបន្តកិច្ចប្រឹងប្រែងរបស់ខ្លួន ដើម្បីរក្សាឱ្យបាននូវកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍សង្គម ក្នុងបរិការណ៍ដែលសេដ្ឋកិច្ចសកលលោកត្រូវប្រឈមនឹងការធ្លាក់ចុះគួរឱ្យបារម្ភ ។ ខ្ញុំយល់ថា កង្វល់នៃវិបត្តិចំពោះមុខនាពេលបច្ចុប្បន្ននេះ មិនគួរគប្បីក្លាយជាឧបសគ្គរារាំង ដល់ការបន្តដំណើរទៅមុខយ៉ាងស្វាហាប់ឆ្ពោះទៅរកការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ប្រកបដោយចិរភាពនោះទេ ។ ផ្ទុយទៅវិញ យើងត្រូវមើលឃើញថា ការប្រឈមទាំងនេះគឺជាមេរៀនដ៏មានតម្លៃ ដែលយើងចាំបាច់ត្រូវប្រែក្លាយឱ្យទៅជាកាលានុវត្តភាពសម្រាប់ដៃគូ ដែលមានការពាក់ព័ន្ធទាំងអស់គ្នា តាមរយៈកិច្ចសហប្រតិបត្តិការ និងការគាំទ្រគ្នាទៅវិញទៅមក ដើម្បីលើកស្ទួយកំណើន និង កាត់បន្ថយភាពក្រីក្រ ។ ក្នុងន័យនេះ យើងត្រូវមានការប្តេជ្ញាចិត្តឥតងាករេ នៅក្នុងការខិតខំប្រឹងប្រែងឈានទៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។ ក្នុងស្មារតីនេះ ខ្ញុំសូមស្នើដល់ដៃគូអភិវឌ្ឍន៍ទាំងអស់ ឱ្យបន្តផ្តល់ការគាំទ្រដល់ កម្ពុជាដូចដែលធ្លាប់

បានធ្វើកន្លងមក ដើម្បីឱ្យកម្ពុជាអាចឈានទៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់ខ្លួនបាន ។

53. ជាការឆ្លើយតបទៅនឹងការយកចិត្តទុកដាក់របស់ដៃគូអភិវឌ្ឍន៍របស់យើង ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមធានាអំពីការប្តេជ្ញាប្រើប្រាស់ធនធានសហប្រតិបត្តិការ ដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍ឱ្យប្រកបដោយប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាពខ្ពស់ ។ រាជរដ្ឋាភិបាលយល់ច្បាស់ណាស់ថាធនធានទាំងនេះ នឹងត្រូវប្រើប្រាស់មិនគ្រាន់តែសម្រាប់គាំទ្រដល់ការផ្តល់សេវាសាធារណៈសំខាន់ៗ ដូចជាសេវាសុខាភិបាល អប់រំ និងការកសាងហេដ្ឋារចនាសម្ព័ន្ធប៉ុណ្ណោះទេ ប៉ុន្តែធនធានទាំងនោះ ក៏នឹងត្រូវបានប្រើប្រាស់ដោយផ្តោតទៅលើការអភិវឌ្ឍន៍សមត្ថភាពធនធានមនុស្ស និងស្ថាប័នផងដែរ ។

54. រាជរដ្ឋាភិបាលសូមវាយតម្លៃខ្ពស់ ចំពោះកិច្ចសហប្រតិបត្តិការ និងការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ទាំងអស់ ។ ខ្ញុំរំពឹងយ៉ាងមុតមាំថា យើងនឹងបន្តកិច្ចសហការជាមួយគ្នាតទៅទៀត ដើម្បីពង្រឹងភាពជាដៃគូឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត សំដៅលើកកម្ពស់កិច្ចសហប្រតិបត្តិការរបស់យើងឱ្យកាន់តែល្អប្រសើរឡើង ដោយឈរលើស្មារតីនៃភាពជាដៃគូដ៏ពិតប្រាកដនិងការគោរពកាន់តែខ្លាំងឡើងនូវ ***«ភាពជាម្ចាស់»*** របស់កម្ពុជា ។ យើងនឹងពិភាក្សាបញ្ហានេះលម្អិតថែមទៀត ហើយខ្ញុំជឿ ថា យើងនឹងឈានទៅរកការឯកភាពគ្នាលើការងារដែលត្រូវរួមគ្នាអនុវត្តបន្តទៅទៀត ។

55. ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះការយកចិត្តទុកដាក់ស្តាប់របស់អស់លោកអ្នកទាំងអស់គ្នា ។ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ***គាត ឈន់*** ដែលជាអ្នកដឹកនាំប្រកបដោយបទពិសោធន៍ និងពោរពេញដោយសមត្ថភាពនឹងតំណាងឱ្យរាជរដ្ឋាភិបាល ក្នុងការដឹកនាំវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី ២ នេះ ។ សហការីរបស់ខ្ញុំនឹងនៅជាមួយអស់លោកអ្នក ហើយធ្វើការចែករំលែកជាមួយអស់លោកអ្នកទាំងអស់គ្នានូវរាល់កម្មវិធី និងព័ត៌មានលម្អិតទាំងឡាយ ដែលទាក់ទិននឹងទិដ្ឋភាពនានា ស្តីពីស្ថានភាពសង្គម- សេដ្ឋកិច្ច និងសេចក្តីត្រូវការរបស់យើងខ្ញុំ ។

56. ខ្ញុំសូមជូនពរដល់អស់លោកអ្នកទាំងអស់គ្នា សូមប្រកបដោយសុខភាពល្អ និងជ័យជំនះក្នុងគ្រប់ភារកិច្ច និង សូមជូនពរឱ្យ **វេទិកានៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ កម្ពុជាលើកទី ២** នេះ ប្រព្រឹត្តទៅបានប្រកបដោយជោគជ័យដ៏ត្រចះត្រចង់ ។

ខ្ញុំសូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់